**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

**លេខ : ០៧២៨/២១ អ គ រ**

ថ្ងៃសៅរ៍ ៦កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១

**ជម្រាបមក**

**លោក លោកស្រីប្រធាននាយកដ្ឋាន សាខា និងការិយាល័យគយនិងរដ្ឋាករ**

**កម្មវត្ថុ៖** ការរំលឹក និងណែនាំបន្ថែមនូវនីតិវិធីគយពាក់ព័ន្ធ ក្នុងអំឡុងពេលនៃការបិទខ្ទប់ភូមិសាស្ត្រមួយចំនួន ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ។

**យោង៖**
- សេចក្តីសម្រេចលេខ ៤៩ សសរ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ប្រកាសលេខ ១៨៤៧ សហវ.ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីបញ្ញត្តិនិងនីតិវិធីប្រតិវេទន៍គយ
- ប្រកាសលេខ ៥០៨ សហវ.ប្រក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការឆ្លងកាត់គយ
- ប្រកាសលេខ ៥៧៥ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យអនុវត្តជំហានដំបូងប្រព័ន្ធបញ្ជរតែមួយជាតិ
- សេចក្តីណែនាំលេខ ១៨៨២/១៩ អគរ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ស្តីពីនីតិវិធីនៃកិច្ចដំណើរការលិខិតអនុញ្ញាតគយតាមប្រព័ន្ធបញ្ជរតែមួយជាតិ
- សេចក្តីណែនាំបន្ថែមលេខ ១៧២៣/២០ អគរ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ស្តីពីនីតិវិធីនៃកិច្ចដំណើរការលិខិតអនុញ្ញាតគយតាមប្រព័ន្ធបញ្ជរតែមួយជាតិ
- លិខិតលេខ ០៨២៩/២០ អគរ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ស្តីពីការកែសម្រួលនីតិវិធីផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយនៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- លិខិតលេខ ០៥៦៣/២១ អគរ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ស្តីពីការកែសម្រួលនីតិវិធីផ្ទៀងផ្ទាត់ឯកសារសំអាងដើមកំណើតដើម្បីអនុវត្តអត្រាពន្ធអនុគ្រោះក្រោមក្របខណ្ឌកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី នៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបលោក លោកស្រី ជ្រាបថា រាជរដ្ឋាភិបាលបានបិទខ្ទប់តំបន់មួយចំនួន ក្នុងគោលដៅទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ ១៩។ ដើម្បីរក្សានិរន្តរភាពការងារ និងធានាបាននូវប្រសិទ្ធភាពនៃកិច្ចសម្រួលពាណិជ្ជកម្ម អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (អគរ) សូមធ្វើការក្រើនរំលឹក និងណែនាំបន្ថែមនូវនីតិវិធីគយមួយចំនួនដូចខាងក្រោម÷

**I. ការអនុវត្តនីតិវិធីចេញលិខិតអនុញ្ញាតគយ ផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ និងផ្ទៀងផ្ទាត់ឯកសារសំអាងដើមកំណើតទំនិញ÷**

- បន្តអនុវត្តតាមខ្លឹមសារក្នុងសេចក្តីណែនាំពាក់ព័ន្ធដូចយោងខាងលើ ដោយធុរជនអាចដាក់ពាក្យស្នើសុំភ្ជាប់ជាមួយឯកសារគាំទ្រនានាតាមមធ្យោបាយអេឡិចត្រូនិច
- អង្គភាពគយនិងរដ្ឋាករមានសមត្ថកិច្ចពាក់ព័ន្ធត្រូវទទួលយក និងប្រើប្រាស់ឯកសារនានាដែលបញ្ជូនតាមមធ្យោបាយអេឡិចត្រូនិចក្នុងប្រព័ន្ធបញ្ជរតែមួយជាតិ និងប្រព័ន្ធស្វ័យប្រវត្តិកម្មផ្សេងទៀត ដើម្បីដំណើរការនីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយ។

**II. ការអនុវត្តនីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយ ÷**

- ប្រតិវេទករអាចដាក់ (Upload) ឯកសារគាំទ្រប្រតិវេទន៍គយ ក្នុង Scan Doc. Tab នៃទម្រង់ប្រតិវេទន៍គយក្នុងប្រព័ន្ធអាស៊ីគូដា ជំនួសឱ្យការដាក់ជាទម្រង់ក្រដាស លើកលែងតែឯកសារដែលមានស្រាប់ ក្នុងប្រព័ន្ធបញ្ជរតែមួយជាតិ និងប្រព័ន្ធ CVDS
- ប្រតិវេទករ ត្រូវបញ្ចូលលេខយោងលិខិតបញ្ជាក់ការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ និង/ឬលេខយោងលិខិតបញ្ជាក់ការផ្ទៀងផ្ទាត់ឯកសារសំអាងដើមកំណើតទំនិញ ដាក់ចូលទៅក្នុង Att. Doc. Tab នៃទម្រង់ប្រតិវេទន៍គយក្នុងប្រព័ន្ធអាស៊ីគូដា
- ជំរុញលើកទឹកចិត្តឱ្យអ្នកនាំចេញ នាំចូលធ្វើការបង់ពន្ធអាករ និងកម្រៃផ្សេងៗតាមរយៈប្រព័ន្ធធនាគារឱ្យអស់លទ្ធភាព។

**III. ការអនុវត្តនីតិវិធីដឹកជញ្ជូនឆ្លងកាត់÷**

- ធុរជន អាចដាក់ពាក្យស្នើសុំគោលការណ៍ដឹកជញ្ជូនឆ្លងកាត់ ភ្ជាប់មកជាមួយឯកសារគាំទ្រនានាក្នុងទម្រង់ PDF តាមប្រព័ន្ធតេឡេក្រាម មកអង្គភាពគយនិងរដ្ឋាករមានសមត្ថកិច្ចដើម្បីពិនិត្យនិងសម្រេច
- អង្គភាពគយនិងរដ្ឋាករមានសមត្ថកិច្ចពាក់ព័ន្ធត្រូវទទួលយក និងប្រើប្រាស់ឯកសារដែលបញ្ជូនតាមប្រព័ន្ធតេឡេក្រាមដូចខាងលើ ដើម្បីដំណើរការនីតិវិធីឆ្លងកាត់។

**IV. ការអនុវត្តនីតិវិធីស្នើសុំផ្សេងទៀត នៅ អគរ÷**

រាល់ការស្នើសុំគោលការណ៍សម្រេចផ្សេងទៀត អាចធ្វើទៅបានតាមប្រព័ន្ធតេឡេក្រាម ដោយត្រូវភ្ជាប់មកជាមួយនូវឯកសារគាំទ្រក្នុងទម្រង់ PDF មក អគរ ដើម្បីពិនិត្យនិងសម្រេច។

ក្នុងករណីចាំបាច់ ប្រតិវេទករ/ ធុរជន ដូចចំណុច I, II, III, IV ខាងលើ អាចតម្រូវឱ្យយកឯកសារពាក់ព័ន្ធក្នុងទម្រង់ក្រដាសមកតម្កល់ទុកជាក្រោយ នាពេលវេលាសមស្រប។

អាស្រ័យហេតុនេះ សូមលោក លោកស្រីចាត់ចែងអនុវត្តតាមខ្លឹមសារនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

សូមលោក លោកស្រី ទទួលនូវការស្រលាញ់រាប់អានពីខ្ញុំ

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកគយនិងរដ្ឋាករកម្ពុជា**

**<u>ចម្លងជូន៖</u>**

- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីជ្រាប និងសហការផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ